ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ២៦៥
ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៨
សាលដីកា
លេខ ៤១ VIII
ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០
ដោយអង្គជំនុំជម្រះដែលមានសមាសភាពដូចខាងក្រោម៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម (របាយការណ៍)

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

## តំណាងមហាអយ្យការ

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៣៥០ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] MACMANUS ដែលបានធ្វើបណ្តឹងតាមរយៈលោកស្រី [redacted] លីនដា ជាអ្នកតំណាងក្នុងការប្តឹងសាទុក្ខ និងបណ្តឹងសាទុក្ខលេខ ៣០១ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] RENE MARIE DUBIGEON



Scanned with CamScanner

ដែលបានធ្វើបណ្តឹងតាមរយៈលោកមេធាវី [redacted] សារ៉ាយ ជាអ្នកតំណាងក្នុងការប្តឹងសាទុក្ខ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៦៦ ក្រ V "វ" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨ សាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន ៖

**បុគ្គលប្តឹងសាទុក្ខ ៖**

**១-ជនជាប់ចោទឈ្មោះ** [redacted] RENE MARIE DUBIGEON ភេទប្រុស អាយុ៤៥ឆ្នាំ ជនជាតិបារាំង មុខរបរប្រធានក្រុមហ៊ុន កាន់លិខិតឆ្លងដែនលេខ 07AT99938 ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ ទីកន្លែងកំណើតឃុំ Nantes ខេត្ត Loire Atlantique។ ទីលំនៅបច្ចុប្បន្ននៅក្នុងអាផាត់មិន [redacted] រាជធានីភ្នំពេញ។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូន ០២ នាក់ ទោសពីមុនគ្មាន ។

មានលោក [redacted] ឡាយ និងលោក [redacted] សដ្ឋារ៉ូ ជាមេធាវីការពារសិទ្ធិ។

ជាប់ចោទពីបទ **បន្លំម៉ាក (ត្រាប់តាម)** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១២ ដល់ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ៦៥ នៃច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ។

**២-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] MACMANUS ភេទប្រុស អាយុ ៤៩ឆ្នាំ ជនជាតិកាណាដា ទីកន្លែងកំណើតប្រទេសកាណាដា។ ទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted] រាជធានីភ្នំពេញ ។

មានលោកស្រីមេធាវី [redacted] សុភាព ជាអ្នកតំណាង ។

**អំពីអង្គហេតុ ៖**

កាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៨ ឈ្មោះ [redacted] RENE MARIE DUBIGEON ភេទប្រុស អាយុ ៤៥ ឆ្នាំ ជនជាតិបារាំង និងឈ្មោះ [redacted] MACMANUS ភេទប្រុស ជនជាតិកាណាដា បានចូលហ៊ុនគ្នាបង្កើតក្រុមហ៊ុនមួយដែលមានឈ្មោះថា ស្មាល រីថេល គ្រុប (SMILE RETAIL GROUP LTD) ហៅកាត់ថា (ក្រុមហ៊ុន) ដោយបានដាក់ទុនម្នាក់ពាក់កណ្តាល ហើយធ្វើការបែងចែកជាភាគហ៊ុន ៥០% (ហាសិបភាគរយ) កាន់កាប់ដោយឈ្មោះ [redacted] MACMANUS និង ៥០% (ហាសិបភាគរយ) ទៀត កាន់កាប់ដោយឈ្មោះ [redacted] RENE MARIE DUBIGEON ។ មានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុនស្មើគ្នា រួមទាំងគណនីទាំងអស់របស់ក្រុមហ៊ុន ។ បន្ទាប់ពីបានការអនុញ្ញាតជាផ្លូវការក្នុងការបង្កើតក្រុមហ៊ុននេះ ជនជាប់ចោទឈ្មោះ [redacted] RENE MARIE DUBIGEON និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] MACMANUS បានបើកផ្សារទំនើបខ្នាតតូចចំនួនប្រាំ ដែលមានឈ្មោះថា Smile Mini Mart ចំនួនប្រាំទីតាំង ក្នុងរាជធានីភ្នំពេញ ។ នៅអំឡុងដើមឆ្នាំ២០១២ ឈ្មោះ [redacted] RENE MARIE DUBIGEON បានធ្វើសកម្មភាពពាណិជ្ជកម្មដើម្បីស្វែងរកផលចំណេញ បានធ្វើឱ្យប៉ះពាល់ដល់



Scanned with CamScanner

ក្រុមហ៊ុន ស្មាល រីថេល គ្រុប (SMILE RETAIL GROUP LTD) ដោយសារឈ្មោះ [redacted] RENE MARIE DUBIGEON បានបង្កើតក្រុមហ៊ុន ស្មាល ដ្រេហ្គន អេស៊ា ហូលឌីង (SMILE DRAGON ASIA HOLDING) ដើម្បីបើកផ្សារទំនើបខ្នាតតូចជាច្រើនកន្លែងក្នុងរាជធានីភ្នំពេញ ដែលមានឈ្មោះថា SMILE DRAGON ខណៈពេលដែលឈ្មោះ [redacted] RENE MARIE DUBIGEON មានតួនាទីជាម្ចាស់ភាគហ៊ុន និងជាប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ស្មាល រីថេល គ្រុប (SMILE RETAIL GROUP LTD) ។ ដើម្បីដំណើរការផ្សារទំនើប SMILE DRAGON ឈ្មោះ [redacted] RENE MARIE DUBIGEON និងឈ្មោះ [redacted] THOMAS JEAN បានធ្វើសកម្មភាពពាណិជ្ជកម្មដោយប្រើប្រាស់ ម៉ាកយីហោ ស្មាល (SMILE) និងឡូហ្គោ (LOGO) របស់ក្រុមហ៊ុន ស្មាល រីថេល គ្រុប (SMILE RETAIL GROUP LTD) មានរូបនាគលើអក្សរ (S) និងពណ៌ ដើម្បីប្រើប្រាស់ជាម៉ាកសម្រាប់ហាង MINI MART របស់ខ្លួន ដោយរំលោភកម្មសិទ្ធិបញ្ញា និងប្រកួតប្រជែងមិនស្មោះត្រង់ចំពោះក្រុមហ៊ុន ស្មាល រីថេល គ្រុប (SMILE RETAIL GROUP LTD) ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៥៩៨ "ហ" ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១. ផ្ដន្ទាទោសលើ ៖

ក. ឈ្មោះ [redacted] RENE MARIE DUBIGEON ភេទប្រុស អាយុ ៤៥ ឆ្នាំ ជនជាតិបារាំង កាន់លិខិតឆ្លងដែនលេខ 07AT99938 ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ ។

ខ. ឈ្មោះ [redacted] THOMAS JEAN ភេទប្រុស ជនជាតិបារាំង កាន់លិខិតឆ្លងដែនលេខ 09AX18488 ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ។

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ០១ (មួយ) ឆ្នាំ ពីបទបន្លំម៉ាក (ត្រាប់តាម) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១២ ដល់ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ៦៥ នៃច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ។

២. ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលើឈ្មោះ [redacted] RENE MARIE DUBIGEON ដើម្បីយកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ ។

៣. ឱ្យឈ្មោះ [redacted] RENE MARIE DUBIGEON និងឈ្មោះ HERBAUT THOMAS JEAN រួមគ្នាសងសំណងការខូចខាត និងជំងឺចិត្តគិតជាប្រាក់រៀលស្មើនឹងប្រាក់ដុល្លារអាមេរិកចំនួន ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] MACMANUS ។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] RENE MARIE DUBIGEON និងឈ្មោះ [redacted] THOMAS JEAN ។ ចំពោះមុខមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ។

បើកផ្លូវឱ្យប្តឹងទាស់និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១៧០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨ របស់លោក [redacted] សារ៉ាយ ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] RENE MARIE DUBIGEON ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៥៩៨ "ហ" ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាលេខ ៦៦ ក្រ V "វ" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១. ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ របស់លោក [redacted] សារ៉ាយ មេធាវីទទួលសិទ្ធិប្តឹងឧទ្ធរណ៍ពីជនជាប់ចោទឈ្មោះ [redacted] RENE MARIE DUBIGEON ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ខ្លះ ។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥៩៨ "ហ" ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ លើកលែងតែសេចក្តីវិនិច្ឆ័យត្រង់ចំណុចទី១-ក នៃសាលក្រមៈ

-ត្រូវការផ្តន្ទាទោសលើឈ្មោះ [redacted] RENE MARIE DUBIGEON ដាក់ពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ ពីបទ បន្លំម៉ាក (ត្រាប់តាម) ប្រព្រឹត្តនៅរាជធានីភ្នំពេញ ក្នុងអំឡុងឆ្នាំ២០១២ ត្រូវកែប្រែមកជាផ្តន្ទាទោសពិន័យជាប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល តែទោសនេះត្រូវព្យួរធម្មតា តាមមាត្រា ៦៥ នៃច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងតាមមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ ។

-និងលើកលែងសេចក្តីវិនិច្ឆ័យត្រង់ចំណុចទី៣ ត្រង់បង្គាប់ឱ្យ [redacted] RENE MARIE DUBIGEON រួមគ្នាសងសំណងការខូចខាត និងជំងឺចិត្តគិតជាប្រាក់រៀលស្មើនឹងប្រាក់ដុល្លារអាមេរិកចំនួន ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ត្រូវកែប្រែមកជា "បង្គាប់ឱ្យឈ្មោះ [redacted] RENE MARIE DUBIGEON សងសំណងការខូចខាត និងជំងឺចិត្តសរុបចំនួន ២៥.០០០ (ពីរម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] MACMANUS" ។

ចំណុចក្រៅពីនេះ រក្សាទុកជាបានការដដែល ។

Scanned with CamScanner

៣. បញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួនលើឈ្មោះ [redacted] RENE MARIE DUBIGEON លេខ ១៤០ "ហ" ដចន ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨ របស់ចៅក្រមជំនុំជម្រះ សាលាដំបូងរាជធានីភ្នំពេញ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៨ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងចំពោះមុខមេធាវីការពារសិទ្ធិដើមបណ្ដឹងរដ្ឋប្បវេណី និងកំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ (ជនជាប់ចោទបានទទួលដំណឹងរួចហើយ) និងកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី តែចាត់ទុកជាចំពោះមុខ ។ ប្រកាសជាសាធារណៈ នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨។

បើកសិទ្ធិប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ៣៥០ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨ របស់លោកស្រីមេធាវី [redacted] លីនដា អ្នកតំណាងដោយអាណត្តិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] MACMANUS ក្នុងការប្ដឹងសាទុក្ខ និងបណ្ដឹងសាទុក្ខលេខ ៣០១ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ របស់លោកមេធាវី [redacted] សារ៉ាយ ជាអ្នកតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] RENE MARIE DUBIGEON ក្នុងការប្ដឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ៦៦ ក្រ V "វ" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្ដីសន្និដ្ឋាននិងប្ដឹងសុំ ដោយលើកឡើងអះអាងថា៖

យល់ឃើញថា

១.បណ្ដឹងសាទុក្ខបានធ្វើឡើង ដោយដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ ហេតុដូច្នេះអានុភាពនៃបណ្ដឹងនេះ គឺមានទៅលើសំណងរដ្ឋប្បវេណីតែប៉ុណ្ណោះ ទោះបីជាដើមបណ្ដឹងរដ្ឋប្បវេណីបានលើកពីមាត្រា ៤១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏ដោយ ។ ម្យ៉ាងទៀត សិទ្ធិអំណាចក្នុងការពិចារណាលើទណ្ឌកម្មគឺជាសមត្ថកិច្ចរបស់តំណាងមហាអយ្យការ ដែលមានតួនាទីប្ដឹងសាទុក្ខ និងការសម្រេចឱ្យអនុវត្តទោសពន្ធនាគារតែប៉ុណ្ណោះ ។

២.ការលើកឡើងរបស់តុលាការអង្គសេចក្ដីថា មានចម្លើយសារភាពរបស់លោក THOMAS ជនជាប់ចោទមួយរូប ក្នុងចំណោមជនជាប់ចោទក្នុងរឿងក្ដីនេះបានសារភាព និងការលើកឡើងក្នុងសារណារបស់ដើមបណ្ដឹង រដ្ឋប្បវេណី ក្នុងចំណុចទី១៨ បានបន្ថែមភស្តុតាងនៃការបន្ដុំ និងការប្រើប្រាស់ម៉ាក Smile នេះ នៅទីតាំងកន្លែង ០២កន្លែង ដូចមានក្នុងកំណត់ហេតុចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ ។

៣.តាមការលើកឡើងរបស់ជនជាប់ចោទលើចំណុចអាជ្ញាអស់ជំនុំតាមមាត្រា ៧ និងមាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៅក្នុងសារណាការពាររបស់ខ្លួន ក៏ពុំទាន់ត្រឹមត្រូវដែរ ដោយសារមាត្រា ២៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងពីលទ្ធភាពនៃការបើកការស៊ើបសួរលើបន្ទុកថ្មីបាន ។



Scanned with CamScanner

៤.តាមអនុស្សារណៈយោគយល់របស់គូភាគីទាំងពីរ ហាក់ដូចជាបានសន្យាបញ្ចប់ ឬទ្រព្យសម្បត្តិក្រុមហ៊ុន Smile Retail Group Ltd. នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១២ ដែលការនេះពិនិត្យឃើញថា ការសារភាពរបស់លោក THOMAS និងរួមទាំងប្រតិបត្តិការផែកផេរនៅទីតាំង ០២ កន្លែងទៀតនោះ គឺបានធ្វើនៅថ្ងៃ១៣ និងថ្ងៃ១៥ ខែមិថុនា ឆ្នាំ២០១២ តែប៉ុណ្ណោះ ដែលមិនបានបញ្ចប់នូវការរំលាយភាគហ៊ុនតាមរយៈអនុស្សារណៈយោគយល់របស់គូភាគីទាំងពីរនៅឡើយទេ ។ ហេតុដូច្នេះ តំណាងមហាអយ្យការប្ដឹងសុំចំពោះតុលាការកំពូលសុំឱ្យក្រុមប្រឹក្សាធ្វើការសាកសួរបន្ថែម ។

+លោក [redacted] សេដ្ឋារ៉ូ ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] Rene Marie Dubigeon បានធ្វើសេចក្ដីសន្និដ្ឋានថា៖ កូនក្ដីរបស់ខ្លួនពុំមានទំនាក់ទំនងជាមួយឈ្មោះ Thomas នោះទេ ពាក់ព័ន្ធជាមួយនឹងការចុះបញ្ជីម៉ាក Smile គឺឈ្មោះ Thomas ធ្វើតែម្នាក់ឯង។ នៅថ្ងៃដែលសមត្ថកិច្ចចុះទៅបង្ក្រាបក៏កូនក្ដីរបស់ខ្លួនមិនបានដឹងដែរ ។ ក្នុងរឿងនេះមានវិមតិសង្ស័យខ្លាំង ខ្លួនសូមបញ្ជាក់ផងដែរថាឈ្មោះ Thomas ក៏មិនបានប្ដឹងសាទុក្ខចំពោះសាលដីការបស់សាលាឧទ្ធរណ៍ដែរ ។ គ្មានភស្តុតាងណាមួយដាក់បន្ទុកមកលើកូនក្ដីរបស់ខ្លួនឡើយ ។ សំណូមពរសុំតុលាការមេត្តាបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ។

+លោក [redacted] ឡាយ ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] Rene Marie Dubigeon បានធ្វើសេចក្ដីសន្និដ្ឋានបន្ថែមថា៖ កម្មសិទ្ធិម៉ាកនោះពុំមែនជាកម្មសិទ្ធិផ្ដាច់មុខរបស់ឈ្មោះ Kirk តែម្នាក់ឯងនោះទេ គឺជាសហកម្មសិទ្ធិ គ្រាន់តែការព្រមព្រៀងចុះអនុស្សារណៈជាមួយគ្នា ឯការចុះកម្មសិទ្ធិម៉ាកទៀតសោត គឺក្នុងនាម [redacted] ជានីតិបុគ្គលរបស់ក្រុមហ៊ុន Smile Retail តែប៉ុណ្ណោះ។ នៅថ្ងៃដែលចុះអនុស្សារណៈយោគយល់គ្នានៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១២ ហើយគូភាគីបានព្រមព្រៀងគ្នាថា ភាគី [redacted] មានសិទ្ធិបន្តរក្សាទុកស្លាកសញ្ញាយីហោ Smile នៅក្នុងហាងរបស់ខ្លួនរហូតដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១២ ជាពេលដែលសម្ភារៈទាំងនេះត្រូវរើចេញពីហាងរបស់ខ្លួន ប្រគល់ហាងទៅឱ្យភាគី [redacted] ។ ចំណែកឯការរំលាយកិច្ចសន្យាឈប់ជួលនៅទីតាំងស្ថានីយ៍ប្រេងឥន្ធនៈសូគីម៉ិចក្បាលថ្នល់ មិនមែនកូនក្ដីរបស់ខ្លួនបញ្ឈប់លែងឱ្យជួលនោះទេ ជាក់ស្ដែងគឺដោយសារតែអគ្គនាយកក្រុមហ៊ុនសូគីម៉ិចធ្វើលិខិតរំលាយកិច្ចសន្យាមកកូនក្ដីខ្លួន ដោយឈប់ជួលបន្តឱ្យក្រុមហ៊ុន Smile Retail ។ ការដែលឈ្មោះ Thomas ជួលឱ្យម្ចាស់ថ្មីពុំមានពាក់ព័ន្ធជាមួយកូនក្ដីរបស់ខ្លួននោះទេ នៅទីតាំងក្បាលថ្នល់ និងនៅផ្លូវ ៣៦០ ដែលមាននិមិត្តសញ្ញា Smile អក្សរ S មានរូបនាគនៅពីលើនោះ គឺក្នុងនាមឈ្មោះ Thomas ជាម្ចាស់ក្រុមហ៊ុនដែលមានឈ្មោះថា Tiger and Lion កូនក្ដីខ្លួនបានចុះបញ្ជីក្រុមហ៊ុនជាមួយឈ្មោះ Thomas មែនពិត ប៉ុន្តែដំណើរការក្រុមហ៊ុន និងការជួលទីតាំងធ្វើអាជីវកម្មលក់ទំនិញ គ្រឿងឧបភោគ បរិភោគនេះ មិនទាន់មានកើតឡើងនូវសកម្មភាពពាណិជ្ជកម្មនៅឡើយទេ គឺកូនក្ដីរបស់ខ្លួនពុំបានដឹងជាមុននោះទេ ទាល់តែប៉ូលិសចុះទៅបង្ក្រាបទើបកូនក្ដីរបស់ខ្លួនបានដឹង។

សំណូមពរ ៖ ស្នើសុំតុលាការមេត្តាបដិសេធសាលដីកាសាលាឧទ្ធរណ៍ និងសម្រេចឱ្យកូនក្ដីរបស់ខ្លួនរួចផុតពីបទចោទប្រកាន់ ដោយក្ដីអនុគ្រោះ ។

Scanned with CamScanner

+លោកស្រី [redacted] សុភាព ជាមេធាវីតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] Macmanus បានធ្វើសេចក្ដីសន្និដ្ឋានថា៖ កូនក្ដីខ្លួនបានចុះបញ្ជីម៉ាក Smile ព្រមទាំងមាននិមិត្តសញ្ញាត្រឹមត្រូវ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ រហូតមកដល់ដើមឆ្នាំ២០១២ ឈ្មោះ [redacted] និងឈ្មោះ Thomas បានចុះបញ្ជីក្រុមហ៊ុនដែលមានឈ្មោះថា Smile Dragon ។ ការស្នើសុំចុះបញ្ជីត្រូវបានគេបដិសេធចោល ដោយមានការតវ៉ាពីកូនក្ដីរបស់ខ្លួន ។ កូនក្ដីខ្លួនមានម៉ាតចំនួន០៥ កន្លែង ហើយលោក Thomas ក៏បានទទួលស្គាល់ផងដែរថា ខ្លួនពិតជាបានប្រើប្រាស់ម៉ាក Smile នោះមែន។ ឯលោក [redacted] គ្មានសិទ្ធិប្រើប្រាស់ម៉ាកនោះទេ។ អ្នកដែលជាម្ចាស់កម្មសិទ្ធិម៉ាកពិតប្រាកដគឺលោក [redacted] តែម្នាក់ប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត ការសម្រេចអំពីសំណងរដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍ធ្វើឡើងដោយមិនបានពិចារណាលើអង្គហេតុ ការចាប់ផ្ដើមនិងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍអាជីវកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងវិស័យផ្សារទំនើបខ្នាតតូច តាំងពីឆ្នាំ២០០៨ មកនោះទេ ដែលធ្វើឱ្យការសម្រេចសេចក្ដីមិនបានផ្ដល់ភាពយុត្តិធម៌ និងធ្វើឱ្យខូចខាតយ៉ាងធ្ងន់ធ្ងរនូវប្រយោជន៍ស្របច្បាប់ របស់ដើមបណ្ដឹងរដ្ឋប្បវេណី។

សំណូមពរ ស្នើសុំតុលាការពិចារណាអំពីសំណងការខូចខាតនិងជំងឺចិត្តឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាននិងប្ដឹងសុំរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីឱ្យជនជាប់ចោទ និងមេធាវីតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

## តុលាការកំពូល

១- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៣៥០ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨ របស់លោកស្រីមេធាវី [redacted] លីនដា ជាអ្នកតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] MACMANUS និងបណ្ដឹងសាទុក្ខលេខ ៣០១ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ របស់លោកមេធាវី [redacted] សារ៉ាយ ជាអ្នកតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] RENE MARIE DUBIGEON ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងក្ដីនេះមកជំនុំជម្រះបាន យោងតាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧ , មាត្រា ៤១៨, ៤២២ និងមាត្រា ៤២២ ត្រង់កថាខណ្ឌទី២ វាក្យខណ្ឌទី១ និងកថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- យល់ឃើញថា ការដែលសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បានសម្រេចអំពីទោស និងប្រកាសទោសលើជនជាប់ចោទឈ្មោះ [redacted] RENE MARIE DUBIGEON ភេទប្រុស ឆ្នាំកំណើត១៩៧១ ជនជាតិបារាំង ពីបទបន្លំម៉ាក (ត្រាប់តាម) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១២ ដល់ឆ្នាំ២០១៥ តាមបទប្បញ្ញត្តិមាត្រា ៦៥ នៃច្បាប់ស្ដីពី ម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដោយសំអាងហេតុត្រង់ចំណុចទី ១២



Scanned with CamScanner

នៃសាលដីកា ថា "ក្រុមប្រឹក្សាយល់ថា តាម MOU ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១២ លោក [redacted] អស់សិទ្ធិប្រើប្រាស់ម៉ាក ពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១២ ប៉ុន្តែលោក BRUNO មានសិទ្ធិបន្តរក្សាទុកឃីហោ SMILE នៅក្នុងហាងរបស់ខ្លួនដែលចែកគ្នាជាមួយលោក [redacted] រហូតដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១២ ប៉ុន្តែលោក [redacted] មិនបានប្រើប្រាស់ ម៉ាក [redacted] នៅហាងខ្លួនទេ បែរជាប្រើប្រាស់ម៉ាក SMILE នេះជាមួយឈ្មោះ THOMAS ក្រោមរូបភាពក្រុម ហ៊ុន SMILE DRAGON រហូតដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ នៅពេលសមត្ថកិច្ចនគរបាលចុះឆែកឆេរទីតាំង និងបង្ក្រាប និងការសន្យាឈប់ប្រើប្រាស់ និងដូរឈ្មោះក្រុមហ៊ុន SMILE DRAGON នៅក្រសួងពាណិជ្ជកម្មនៅ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ ។ ដូច្នេះក្រុមប្រឹក្សាយល់ថា រយៈពេលប្រើប្រាស់ម៉ាក SMILE ដោយរំលោភបំពាន មានរយៈពេលខ្លីទេ គឺពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ ជាថ្ងៃដែលក្រសួង ពាណិជ្ជកម្មទទួលចុះបញ្ជីកែប្រែឈ្មោះក្រុមហ៊ុនរបស់លោក [redacted] ជាផ្លូវការពីឈ្មោះ SMILE DRAGON ASIA HOLDING CO LTD ទៅ SOLUTION DELTA ASIA HOLDING CO LTD តាមលិខិតលេខ ៤៥១៥ ព.ណ ចបព ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ ដែលការនេះបង្ហាញច្បាស់ថា ពីរយៈពេលប្រើប្រាស់ម៉ាក រំលោភដោយលោក BRUNO ,THOMAS និងឥន្ទ្រៈឈប់ប្រើប្រាស់ម៉ាក SMILE តាមការព្រមព្រៀង MOU ចុះ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១២ របស់លោក [redacted]។ ជារួមរយៈពេលប្រើប្រាស់ម៉ាក SMILE និងឈ្មោះ SMILE របស់លោក [redacted] និងលោក THOMAS គឺមានរយៈពេល ០១ ខែ និង ០៩ ថ្ងៃ ប៉ុណ្ណោះនោះ តុលាការកំពូល ពិចារណាឃើញថា សំអាងហេតុនេះពុំទាន់គ្រប់គ្រាន់ដើម្បីកំណត់ពិរុទ្ធភាពលើឈ្មោះ BRUNORENE MARIE DUBIGEON នោះទេ ពីព្រោះថា ជនជាប់ចោទឈ្មោះ [redacted] RENE បានឆ្លើយបដិសេធគ្រប់ដំណើរការនៃកិច្ចនីតិវិធីថា ខ្លួនមិនបានដឹង និងមិនបានប្រើប្រាស់ម៉ាក SMILE ដោយក្លែងបន្លំឡើយ គឺឈ្មោះ THOMAS ទេដែលជាអ្នកប្រើប្រាស់ ដែលចម្លើយនេះមានភាពស៊ីចង្វាក់ ទៅនឹងកំណត់ហេតុរបស់សមត្ថកិច្ចនគរបាលដែលចុះឆែកឆេរទីតាំង និងបង្ក្រាប ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ បានរកឃើញសញ្ញាម៉ាក SMILE នោះស្ថិតនៅនឹងទីតាំងរបស់ឈ្មោះ THOMAS ដែលមានក្រុមហ៊ុនឈ្មោះ TIGER & LION ហើយក៏ស៊ីចង្វាក់ទៅនឹងលិខិតសុំទោសចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១២ ដែលឈ្មោះនេះធ្វើការសុំទោសតែម្នាក់ឯង មិនពាក់ព័ន្ធនឹងឈ្មោះ BRUNORENE ឡើយ។ ក្រៅពីសមត្ថកិច្ចចុះឆែកឆេរនៅទីតាំងរបស់ឈ្មោះ THOMAS គឺពុំមានភស្តុតាងណាបញ្ជាក់ថា ឈ្មោះ BRUNO RENE បានប្រើប្រាស់ម៉ាក SMILE ធ្វើឱ្យមានការខូចខាតដល់ដើមបណ្តឹងរដ្ឋប្បវេណីនោះដែរ។ ម្យ៉ាងទៀតក្រោយពីមានការចុះបង្ក្រាបភាគីដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទបានចុះអនុស្សារណៈយោគយល់គ្នា នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១២ ហើយមានខចែងថា "ភាគី [redacted] និងមានសិទ្ធិបន្តរក្សាទុកស្លាកយីហោ Smile នៅក្នុងហាងរបស់ខ្លួនរហូតដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១២" ទៀតផង។ ឯតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បានធ្វើសេចក្តីសន្និដ្ឋានដូចមានលើកឡើងក្នុងសំអាងហេតុត្រង់ចំណុចទី១០ នៃសាលដីកាសាលាឧទ្ធរណ៍ថា "តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា _"នេះជាវិវាទពាក់ព័ន្ធពាណិជ្ជកម្ម សូមឱ្យពិចារណាពីបទចោទប្រកាន់_ ។ _អង្គហេតុគឺ ដាក់អំឡុងឆ្នាំ២០១២ ដល់ឆ្នាំ២០១៤។ ក្នុងរឿងនេះភាគីបានប្តឹងរក្សាការពារហើយ។ បុគ្គលដែលយកផ្លាក_

Scanned with CamScanner

*សញ្ញា ទៅចុះបញ្ជីពាណិជ្ជកម្ម ហើយក្រសួងពាណិជ្ជកម្មទទួលស្គាល់ខុសដែរឬទេ"* ហើយសេចក្តីសន្និដ្ឋាននេះក៏ស្របគ្នា ទៅនឹងសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលដែរ ដែលបានសន្និដ្ឋានថា "សាលាឧទ្ធរណ៍ សម្រេចសេចក្តីលើជនត្រូវចោទរូបនេះមិនទាន់ត្រឹមត្រូវទេ ពីព្រោះថា ការចុះឆែកឆេររបស់មន្ត្រីនគរបាលយុត្តិធម៌ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ ក្រោយមកដល់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១២ ទើបមានអនុសារណៈយោគយល់គ្នា ដែលមានខចែងថា *"អំពីការព្រមព្រៀងគ្នារវាងដើមបណ្តឹង និងជនត្រូវចោទ"* ដែលសេចក្តីសន្និដ្ឋាននេះមានភាពសមហេតុផល និងស្របជាមួយនឹងការយល់ឃើញខាងលើរបស់អង្គជំនុំជម្រះ។

៣- យល់ឃើញថា តាមសំអាងហេតុត្រង់ចំណុចទី២ ខាងលើបង្ហាញឱ្យឃើញថា គ្មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted]RENE ពីបទ បន្លំម៉ាក (ត្រាប់តាម) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១២ ដល់ឆ្នាំ២០១៥ តាមបទប្បញ្ញត្តិមាត្រា ៦៥ នៃច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលជាហេតុតុលាការកំពូលគប្បីសម្រេចឱ្យឈ្មោះ [redacted] RENE រួចខ្លួនពីបទចោទតាមបទប្បញ្ញត្តិមាត្រា ៣៥០ កថាខណ្ឌទី៣ និងមាត្រា ៤៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤- យល់ឃើញថា យោងតាមបទប្បញ្ញត្តិមាត្រា ២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការព្រហ្មទណ្ឌពុំអាចសម្រេចឱ្យជនជាប់ចោទទទួលជួសជុលព្យសនកម្មបានទេ ដោយហេតុថា ជនជាប់ចោទពុំមានពិរុទ្ធភាព។

៥. យល់ឃើញថា ការដែលលោកស្រីមេធាវី ធីម សុភាព ជាអ្នកតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]MACMANUS បានលើកឡើងក្នុងសារណាការពាររបស់ខ្លួន ក៏ដូចជាសេចក្តីសន្និដ្ឋាននាពេលសវនាការដែរថា សាលាឧទ្ធរណ៍បានសម្រេចផ្តន្ទាទោសលើជនជាប់ចោទស្រាល និងឱ្យសងសំណងតិចនោះ គឺពុំមែនជាមូលហេតុ នៃបណ្តឹងសាទុក្ខ ដែលមានបញ្ញត្តក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះទេ។

៦- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៦៦ ក្រ V "វ" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីចំពោះជនជាប់ចោទឈ្មោះ BRUNO RENE ពុំត្រឹមត្រូវតាមគតិច្បាប់ទេ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ ៣០១ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥ របស់លោកមេធាវី [redacted] សារ៉ាយ ជាអ្នកតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted]RENE MARIE DUBIGEON ទុកជាត្រឹមត្រូវតាមច្បាប់។

២- បដិសេធបណ្តឹងសាទុក្ខលេខ ៣៥០ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨ របស់លោកស្រីមេធាវី ហួត លីនដា ជាអ្នកតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]MACMANUS ដោយខុសនឹងគតិច្បាប់។



Scanned with CamScanner

៣- បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៦៦ ក្រ V "វ" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ផ្នែកសេចក្ដីសម្រេចចំពោះជនជាប់ចោទឈ្មោះ [redacted] RENE MARIE DUBIGEON ។

៤- ឱ្យជនជាប់ចោទឈ្មោះ [redacted] RENE MARIE DUBIGEON រួចខ្លួនពីបទបន្លំម៉ាក (ត្រាប់តាម) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១២ ដល់ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោស តាមបទប្បញ្ញត្តិមាត្រា ៦៥ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ។ តាមបទប្បញ្ញត្តិមាត្រា ៣៥០ កថាខណ្ឌទី៣ និងមាត្រា ៤៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៥- ឱ្យជនជាប់ចោទឈ្មោះ [redacted] RENE MARIE DUBIGEON រួចផុតពីការទទួលខុសត្រូវខាងសំណងរដ្ឋប្បវេណី ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ។

Scanned with CamScanner